ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

គាំពារសង្គមកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី២២)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ០៨៩ នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៦ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៦ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ១១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៤៦ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 27 |
| 1 | ក្រុមហ៊ុន ជា ស៊ីណាត ហ្គាមេន ខូ អិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ស៊ូ ហ្វីយ៉ា (ខេមបូឌា) អឹភែរឹល ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ជូស្តារ អ៊ិនជាសស្រៀល | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ស៊ីន ឥុង យាន ព្រីងធីង ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ម៉ាក ប៊ែក (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ហ្វូសាន់នី ហ្គាមេន | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ថៃយ៉ូ កូហ្គីយ៉ូ (ខេមបូឌា) | ភ្នំពេញ |
| 8 | ក្រុមហ៊ុន សិន តៃ ហ្គាមេន (ខេមបូឌា) | ភ្នំពេញ |
| 9 | ក្រុមហ៊ុន យើង ហ្សេសិន ហ្គាមេន | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ម៉េងដា ហ្វូតវៀរ អ៊ីនដាស់ស្ទ្រីល | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ញូ សេនស៏ ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 12 | ក្រុមហ៊ុន រួយ ជា ស៊ីង ហ្គាម៉ិន | ភ្នំពេញ |
| 13 | ក្រុមហ៊ុនភើហ្វម វែល ហូលឌីង (ខេមបូឌា) លីមីធីត | កណ្តាល |
| 14 | ក្រុមហ៊ុន ណាហ្គាភីស ឧបភើរេសិន លីមីធីត_1 | កណ្តាល |
| 15 | ក្រុមហ៊ុន ហប ឡុក (ខេមបូឌា) ឯ.ក | កណ្តាល |
| 16 | ក្រុមហ៊ុន សាងវ៉ូ ខេមបូឌា ខូអិលធីឌី | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ចិចសាន់(ខេមបូឌា)នីតធីង វ៉ស៊ីង ដាយអ៊ីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ទ្រីនីធី ហ៊ែនប៊ែក ខូអិលធីឌី | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុន ហ្គ្រេត ភីស លីមីធីត | កំពង់ស្ពឺ |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 21 | ក្រុមហ៊ុន ហ៍រសេងដារ ហ្វ៊ីបភើ (ខេម) | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុន ស្ត្រង ហែលធ៏ អ៊ិនធើណេសិនណល លីមីធីត | តាកែវ |
| 23 | ក្រុមហ៊ុន ហាជ័រអ៊ិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |
| 24 | ក្រុមហ៊ុន ចឹងស្រេង អ៊ិនដាសស្ទ្រៀល | តាកែវ |
| 25 | ក្រុមហ៊ុន ស្កាយណាយ2 អ៊ិនធើណេសិនណល ខូអិលធីឌី | កំពង់ចាម |
| 26 | ក្រុមហ៊ុន វ៉ាន់ធីជ រីវើរ ថេកស្តាយ | ព្រះសីហនុ |
| 27 | ក្រុមហ៊ុន កៅវ៉េ ស្ព័ត អិលធីឌី | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 19 |
| 28 | សណ្ឋាគារ អូឡាំព្យា ស៊ីធី | ភ្នំពេញ |
| 29 | ក្រុមហ៊ុន បារអាតហ្គូត | ភ្នំពេញ |
| 30 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 31 | ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 32 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 33 | ក្រុមហ៊ុន ហ៊្វូដឡាយហ្វ៍ | ភ្នំពេញ |
| 34 | សណ្ឋាគារ ប៉ាស៊ីហ្វិក អូតែល | ភ្នំពេញ |
| 35 | សណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ | ភ្នំពេញ |
| 36 | សណ្ឋាគារ ភ្នំពេញ អេរ៉ា ហូថេល ឯ.ក | ភ្នំពេញ |
| 37 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 38 | សណ្ឋាគារ សុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 39 | ក្រុមហ៊ុន ផូរិចអេស៊ា | សៀមរាប |
| 40 | ក្រុមហ៊ុន ហ៊្វូដ អេន បេវើរិច សឺលូសិន | សៀមរាប |
| 41 | ក្រុមហ៊ុន អញ្ជលី បាយ ស៊ីផុន | សៀមរាប |
| 42 | សណ្ឋាគារ ម៉ាល់ បើរី បូទិច អូតែល | សៀមរាប |
| 43 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 44 | សណ្ឋាគារ បាយ៉ន អេរ៉ា ហូថែល ខបភើរេសិន | សៀមរាប |
| 45 | សណ្ឋាគារទ្រីឡាញ អឺបេន រីហ្សត | សៀមរាប |
| 46 | សណ្ឋាគារស្ទឹងសៀមរាបថ្មី | សៀមរាប |